**អនុក្រឹត្យ លេខ ៥១ អនក្រ.បក**

**ស្តីពី**

**ការបង្កើតមហាវិទ្យាល័យ នំរតុន**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតនិងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាឯកទេស
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧-១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់នាយកមជ្ឈមណ្ឌលបាណាណា និងក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

មាត្រា ១._ អនុញ្ញាតអោយបង្កើតមហាវិទ្យាល័យឯកជនមួយដែលមានឈ្មោះថា «**មហាវិទ្យាល័យ នំរតុន**» មហាវិទ្យាល័យនេះមានទីតាំងនៅផ្ទះលេខ ១៥២ ផ្លូវលេខ ១០៨ សង្កាត់ផ្សារចាស់ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មាត្រា ២._ ចំពោះមុខការសិក្សានៅមហាវិទ្យាល័យ នំរតុន មាន ៤ផ្នែក :

| | |
|---|---|
| ១_ច្បាប់ | មានរយៈពេល ៤ឆ្នាំ |
| ២_វិទ្យាសាស្ត្រសេដ្ឋកិច្ច | មានរយៈពេល ៤ឆ្នាំ |
| ៣_ពាណិជ្ជសាស្ត្រ | មានរយៈពេល ៤ឆ្នាំ |
| ៤_វិទ្យាសាស្ត្រកុំព្យូទ័រ | មានរយៈពេល ៤ឆ្នាំ |

ទៅអនាគតមហាវិទ្យាល័យ នឹងបើកផ្នែកផ្សេងៗតាមលទ្ធភាព និងតម្រូវការសង្គម ។

មាត្រា ៣.~លក្ខខណ្ឌទទួលសិស្សអោយចូលរៀន

បេក្ខជនទាំងពីរភេទជាសិស្ស និស្សិត ជាប្រជាពលរដ្ឋ និងជាមន្ត្រីរាជការ ដែលមានសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ឬ សញ្ញាប័ត្រមានតំលៃស្មើ ។

មាត្រា ៤.~លោក **ចាន់ សុខឃាង** មានភារកិច្ច :

_ជ្រើសរើសសិស្សអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន ។

_គ្រប់គ្រងអោយបាននូវដំណើរការបង្រៀន ឯកសារសិក្សា ការប្រឡង និងការប្រគល់សញ្ញាប័ត្រ ។

_គោរព និងអនុវត្តតាមសារាចរ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល

_ធានាអោយបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម

_រាយការណ៍រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំយុវជន និងកីឡា

មាត្រា ៥.~ក្រសួងអប់រំយុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យ ហើយមានសិទ្ធិស្នើសុំបិទប្រសិនបើសាលានេះអនុវត្តខុសពីច្បាប់រដ្ឋ ។

មាត្រា ៦.~និស្សិតដែលរៀនចប់កម្មវិធីសិក្សា នឹងទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សានឹងបានទទួលបរិញ្ញាប័ត្រឧត្តមសិក្សា ដែលផ្តល់ដោយមហាវិទ្យាល័យ នំវតុន ។

មាត្រា ៧.~ក្រសួងអប់រំយុវជន និងកីឡា អគ្គនាយកដ្ឋាន និង អង្គភាពដែលពាក់ព័ន្ធជាមួយនឹងលោក **ចាន់ សុខឃាង** មានភារកិច្ចរៀងៗខ្លួនអនុវត្តនិងប្រតិបត្តិតាមសេចក្តីសំរេចនេះ។

មាត្រា ៨.~អនុក្រឹត្យនេះមានប្រសិទ្ធភាព គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា ហត្ថលេខានិងត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

* * *